# របាយការណ៍ស្តីពីលទ្ធផលការបើកវគ្គបណ្តុះបណ្តាល
# កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
# ( ថ្ងៃទី ១៨-២៨ ឧសភា ២០១០)

ដើម្បីពង្រឹង និង លើកកម្ពស់ការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ ក្រុមកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំបើកវគ្គបណ្តុះបណ្តាលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដល់មន្ត្រីសម្របសម្រួលខេត្ត/ស្រុក មន្ត្រីគាំទ្របច្ចេកទេស មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពថ្នាក់ខេត្ត ទីប្រឹក្សារដ្ឋបាលមូលដ្ឋាន និង ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ ។ វគ្គបណ្តុះបណ្តាលនេះត្រូវបានអនុវត្តជា៤វគ្គផ្សេងគ្នានៅតាមថ្នាក់តំបន់ទាំង៤គឺ: (១) នៅតំបន់ព្រះសីហនុ (មានចំនួន៤ ខេត្ត : ខេត្តព្រះសីហនុ កោះកុង កំពត និង កែប) បានប្រព្រឹត្តិទៅនៅសាលប្រជុំ នៃគ.ប្រខេត្តកោះកុង ចាប់ពី ថ្ងៃទី ១៨-១៩ ខែ ឧសភា ឆ្នាំ ២០១០ (២) នៅតំបន់កំពង់ស្ពឺ (មានចំនួន៧ ខេត្ត : ខេត្តកំពង់ស្ពឺ តាកែវ កណ្តាល ព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង និង ពោធិ៍សាត់) បានប្រព្រឹត្តិទៅនៅសាលប្រជុំនៃ គ.ប្រខេត្តកំពង់ស្ពឺ ចាប់ពីថ្ងៃទី ២០-២១ ខែ ឧសភា ឆ្នាំ ២០១០, នៅតំបន់ក្រចេះ (មានចំនួន៥ខេត្ត: ខេត្តក្រចេះ កំពង់ចាម ស្ទឹងត្រែង រតនគីរី និង មណ្ឌលគីរី) បានប្រព្រឹត្តិទៅនៅសាលប្រជុំនៃគ.ប្រខេត្តកំពង់ចាម ចាប់ពីថ្ងៃទី ២៤-២៥ ខែ ឧសភា ឆ្នាំ ២០១០, និង នៅតំបន់សៀមរាប (មានចំនួន៧ខេត្ត : ខេត្តសៀមរាប កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង និង បៃលិន) បានប្រព្រឹត្តិទៅនៅសាលប្រជុំ នៃគ.ប្រខេត្តកំពង់ធំ ចាប់ពីថ្ងៃទី ២៧-២៨ ខែ ឧសភា ឆ្នាំ ២០១០ ។ សិក្ខាកាម និងអ្នកចូលរួមសរុបទាំងបួនវគ្គមានចំនួន ១៦២ នាក់ (ស្ត្រីចំនួន ១៥ នាក់) ក្នុងនោះវគ្គនៅខេត្តកោះកុងចំនួន ៣២នាក់ វគ្គនៅខេត្តកំពង់ស្ពឺចំនួន ៥0 នាក់ វគ្គនៅខេត្តកំពង់ចាមចំនួន ៣៨ នាក់ និង វគ្គនៅខេត្តកំពង់ធំមាន ៤២ នាក់ ។

## គោលបំណងវគ្គបណ្តុះបណ្តាលៈ

- ដើម្បីបង្កើនសមត្ថភាពចំណេះដឹងផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ក្នុងក្របខ័ណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ ដល់សិក្ខាកាមជាមន្ត្រីថ្នាក់ខេត្ត/ស្រុក ផ្នែករដ្ឋបាលមូលដ្ឋាន ជនបង្គោលទទួលបន្ទុកការងារកិច្ចការពារសុវត្ថិភាព មន្ត្រីផ្នែកគាំទ្របច្ចេកទេស និងទីប្រឹក្សាគម្រោង ។
- ដើម្បីចែករំលែកចំណេះដឹង មេរៀន និងបទពិសោធន៍ទាក់ទងទៅនឹងការអនុវត្តកិច្ចការពារសុវត្ថិភាពទាំងបីផ្នែក (បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច) ក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ ។

- ដើម្បីពង្រឹងការចែករំលែកចំណេះដឹង បទពិសោធន៍ និងជួយគាំទ្រដល់ផ្នែកកិច្ចការពារសុវត្ថិភាព បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដល់មន្ត្រីពាក់ព័ន្ធនានា និងក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ដើម្បីបង្កើនការអនុវត្តផ្នែកកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខ័ណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ ឱ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់ ។

**វិធីសាស្ត្រអនុវត្តក្នុងវគ្គបណ្តុះបណ្តាលៈ**

- ការធ្វើបទបង្ហាញរបស់អ្នកសម្របសម្រួល ផ្តោតសំខាន់លើការអនុវត្តជាក់ស្តែង ដោយបង្ហាញ និង ពន្យល់បកស្រាយលម្អិតអំពីដំណើររបស់កិច្ចការពារសុវត្ថិភាពនីមួយៗ ជាមួយនឹងការអនុវត្ត និងការបំពេញទម្រង់នីមួយៗ
- ការអនុវត្តលំហាត់សាកល្បង ដោយផ្សារភ្ជាប់រវាងគោលការណ៍ណែនាំ និង បទពិសោធន៍ជាក់ស្តែង
- ការពិភាក្សាជាក្រុមតូច និង ក្រុមធំ និង សំណួរ ចម្លើយ
- ការវាស់វែង វាយតម្លៃការយល់ដឹងរបស់សិក្ខាកាម តាមរយៈបំពេញបញ្ជីសំណួរ
- ការចែករំលែកចំណេះដឹង និងបទពិសោធន៍ រវាងសិក្ខាកាម

**លទ្ធផលសម្រេចបានពីវគ្គបណ្តុះបណ្តាលៈ**

ពិនិត្យជារួមវគ្គបណ្តុះបណ្តាលទាំងបួនវគ្គនេះ សិក្ខាកាមមានការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ខ្ពស់ស្តាប់នូវរាល់ការពន្យល់បកស្រាយរបស់អ្នកសម្របសម្រួល និងគ្រូឧទ្ទេស នូវរាល់មេរៀន និង បទពិសោធន៍ ទាំងឡាយដែលទាក់ទងទៅនឹងកិច្ចការពារសុវត្ថិភាពទាំងបី ។ ជាងនេះទៅទៀតសិក្ខាកាមភាពច្រើន មានភាពសកម្ម និង ផុលផុសចំពោះការពិភាក្សា ការជជែកវែកញែកអំពីបញ្ហា និង ហេតុផលទាំងឡាយដែលពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាព ព្រមជាមួយការបង្ហាញពីបទពិសោធន៍ដែលបានអនុវត្តជាក់ស្តែង នឹងផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តី និងគោលការណ៍ណែនាំដែលបានចែងក្នុងសៀវភៅភីម ដែលសុទ្ធសឹងតែ ជាការចែករំលែកនូវបទពិសោធន៍ល្អៗរវាងសិក្ខាកាម និង ក្រុមអ្នកសម្របសម្រួល ។

តាមរយៈស្វ័យវាយតម្លៃរបស់សិក្ខាកាមម្នាក់ៗ ចំពោះការយល់ដឹងផ្នែកកិច្ចការពារសុវត្ថិភាពទាំងបី បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលទាំងបួនវគ្គនេះ បានបង្ហាញឱ្យឃើញលទ្ធផលបង្ហាញក្នុងតារាងខាងក្រោមៈ

**១- វគ្គបណ្តុះបណ្តាលនៅខេត្តកោះកុងៈ**

| **កំរិតយល់ដឹងរបស់សិក្ខាកាម** |
|---|

| និទ្ទេស | ខ្សោយ | | | មធ្យម | | ល្អបង្គួរ | | ល្អ | | ល្អណាស់ |
|---|---|---|---|---|---|---|---|---|---|---|
| កម្រិតពិន្ទុ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
| កិច្ចការពារសុវត្ថិភាពបរិស្ថាន | | | | | | | ៥ នាក់ | ៤ នាក់ | ៨ នាក់ | ១ នាក់ |
| កិច្ចការពារសុវត្ថិភាពដីធ្លី | | | | | | ១ នាក់ | ៣ នាក់ | ៣ នាក់ | ៩ នាក់ | ២ នាក់ |
| កិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិច | | | | | ១ នាក់ | ៣ នាក់ | ៣ នាក់ | ៤ នាក់ | ៧ នាក់ | |

## ២- វគ្គបណ្តុះបណ្តាលនៅខេត្តកំពង់ស្ពឺ:

| ការយល់ដឹងរបស់សិក្ខាកាម | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| និទ្ទេស | ខ្សោយ | | | មធ្យម | | ល្អបង្គួរ | | ល្អ | | ល្អណាស់ |
| កម្រិតពិន្ទុ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
| កិច្ចការពារសុវត្ថិភាពបរិស្ថាន | | | | ១នាក់ | ១នាក់ | | ៧នាក់ | ១១នាក់ | ១៣នាក់ | ១នាក់ |
| កិច្ចការពារសុវត្ថិភាពដីធ្លី | | | | ១នាក់ | ១នាក់ | ១នាក់ | ៤នាក់ | ១៤នាក់ | ៩នាក់ | ៣នាក់ |
| កិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិច | | | | ១នាក់ | | ២នាក់ | ៧នាក់ | ១០នាក់ | ១០នាក់ | ១នាក់ |

## ៣- វគ្គបណ្តុះបណ្តាលនៅខេត្តកំពង់ចាម:

| ការយល់ដឹងរបស់សិក្ខាកាម | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| និទ្ទេស | ខ្សោយ | | | មធ្យម | | ល្អបង្គួរ | | ល្អ | | ល្អណាស់ |
| កម្រិតពិន្ទុ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
| កិច្ចការពារសុវត្ថិភាពបរិស្ថាន | | | | | ១នាក់ | ៤នាក់ | ៣នាក់ | ១១នាក់ | ៣នាក់ | ២នាក់ |
| កិច្ចការពារសុវត្ថិភាពដីធ្លី | | | | | ២នាក់ | ២នាក់ | ៤នាក់ | ៩នាក់ | ៥នាក់ | ២នាក់ |
| កិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិច | | | | | ១នាក់ | ៣នាក់ | ៦នាក់ | ៨នាក់ | ៣នាក់ | ៣នាក់ |

## ៤- វគ្គបណ្តុះបណ្តាលនៅខេត្តកំពង់ធំ:

| ការយល់ដឹងរបស់សិក្ខាកាម |
|---|

| និទ្ទេស | ខ្សោយ | | | មធ្យម | | ល្អបង្គួរ | | ល្អ | | ល្អណាស់ |
|---|---|---|---|---|---|---|---|---|---|---|
| កម្រិតពិន្ទុ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
| កិច្ចការពារសុវត្ថិភាពបរិស្ថាន | | | | | | | ១០នាក់ | ៨នាក់ | ៨នាក់ | |
| កិច្ចការពារសុវត្ថិភាពដីធ្លី | | | | | | | ១២នាក់ | ៨នាក់ | ៦នាក់ | |
| កិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិច | | | | | | ៤នាក់ | ១១នាក់ | ៥នាក់ | ៦នាក់ | |

***សំគាល់:*** *ចំពោះការវាយតម្លៃដែលបានបង្ហាញក្នុងតារាងទាំងបួនខាងលើនេះ មានសិក្ខាកាមមួយចំនួនមិនបានប្រគល់ក្រដាសវាយតម្លៃ មកអ្នកសម្របសម្រួល ដើម្បីបូកសរុបបញ្ចូលក្នុងតារាងខាងលើនេះឡើយ ។*

**សំណូមពរ និង អនុសាសន៍ផ្សេងៗពីសិក្ខាកាមៈ**

**វគ្គបណ្តុះបណ្តាលនៅខេត្តកោះកុង**

- សូមឱ្យថ្នាក់ជាតិរៀបចំបើកវគ្គនេះនៅពេលក្រោយៗទៀតមានចំនួនថ្ងៃច្រើនជាងនេះ ដោយលើកយកឧទាហរណ៍ ចំពោះការអនុវត្តជាក់ស្តែង ពិសេសនូវរាល់ចំណុចល្អៗបន្ថែមទៀត ដើម្បីចែករំលែកដល់សិក្ខាកាម ពិសេសសូមឱ្យមានការផ្សារភ្ជាប់វគ្គ ទៅនឹងការចុះអនុវត្តសាក់ល្បងនៅទីវាលផង
- សូមឱ្យថ្នាក់ជាតិផលិត និងផ្តល់រូបភាពផ្ទាំងប៉ុស្ទ័រ ដែលបង្ហាញពីការងារការពារសុវត្ថិភាពទាំងបី ផ្សព្វផ្សាយតាមបណ្តាខេត្ត
- សូមឱ្យថ្នាក់ជាតិបើកវគ្គនេះលើកក្រោយ ឱ្យអញ្ជើញមន្ទីរវិស័យពាក់ព័ន្ធចូលរួមផង ជាពិសេសអាជ្ញាធរដែនដី ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងពិគ្រោះមតិយោបល់ចំពោះការងារកិច្ចការពារសុវត្ថិភាព នៃគម្រោងឃុំ សង្កាត់ និងបង្កភាពងាយស្រួលក្នុងកិច្ចសហការ គាំទ្រអនុវត្តការងារ
- វគ្គបណ្តុះបណ្តាលនេះល្អ តែមានការយឺតយ៉ាវក្នុងការបើកវគ្គនេះ សូមឱ្យឆ្នាំក្រោយ បើកវគ្គនេះនៅកំឡុងខែកុម្ភៈ ឬ មីនា ទើបស្របនឹងការរៀបចំគម្រោងនៅមូលដ្ឋាន
- សំណូមពរឱ្យបង្ហាញពីលទ្ធផលនៃការអនុវត្ត ជាមួយនឹងបទពិសោធន៍ជាក់ស្តែងឱ្យបានច្រើនជាងនេះ នៅពេលបើកវគ្គលើកក្រោយទៀត
- តើការកំនត់តំបន់ឃ្លាំមើលបរិស្ថាន ផ្អែកលើកត្តាអ្វីខ្លះ និងកំណត់យ៉ាងដូចម្តេច ? ខ្ញុំយល់ថាតំបន់ខ្លះ ហាក់ដូចមិនមានផងប៉ះពាល់បរិស្ថានទេ តែបែជាស្ថិតក្នុងតំបន់ឃ្លាំមើលបរិស្ថាន
- បទពិសោធន៍គួរយកពីខេត្តមុំតំបន់ឆ្នេរ ជាឧទាហរណ៍ ដែលមានភូមិសាស្ត្រប្រហែលគ្នា នាំឱ្យងាយស្រួល ដល់សិក្ខាកាមយល់ និង យកទៅអនុវត្ត ។

**វគ្គបណ្ដុះបណ្ដាលនៅខេត្តកំពង់ស្ពឺ**

- គួររៀបចំជាវីដេអូស្ពត បង្ហាញអំពីដំណើរការនីមួយៗនៃការសិក្សាកិច្ចការពារសុវត្ថិភាពទាំងបី ចែកជូនតាមខេត្ត ជាពិតិមានបន្ថែមក្នុងការផ្ដល់ចំណេះដឹងដល់ថ្នាក់មូលដ្ឋាន ពិសេសឃុំ សង្កាត់
- ត្រូវមានវគ្គរំលឹកនេះជារៀងរាល់ឆ្នាំ ហើយវគ្គបណ្ដុះបណ្ដាលត្រូវមានរយៈពេលវែងជាងនេះបន្តិច ដើម្បីមានឱកាសគ្រប់គ្រាន់ ក្នុងការរៀនសូត្រដកបទពិសោធន៍ការអនុវត្តជាក់ស្ដែងពីខេត្តផ្សេងៗ
- ការបើកវគ្គនេះគួរតែបើកនៅខែកុម្ភៈ ឬ មីនាឱ្យស្របនឹងពេលកំពុងសិក្សាគម្រោង
- ពេលចប់វគ្គបណ្ដុះបណ្ដាលគួរមានលិខិតបញ្ជាក់ការសិក្សាចែកជូនសិក្ខាកាមចូលរួមវគ្គ
- គួរឧបត្ថម្ភប្រាក់ DSA ច្រើនជាងនេះ គួរតែផ្ដល់ ២៥ ទៅ ៣០ ដុល្លារ ម្នាក់ក្នុងមួយថ្ងៃ
- គួរប្ដូរទីកន្លែងនៃការបើកវគ្គបណ្ដុះបណ្ដាល ឧៈ ទៅខេត្តរតនគិរី មណ្ឌលគិរី ជាដើម ។ល។
- គួរមានកាតាបយួរចែកជូនសិក្ខាកាម

**វគ្គបណ្ដុះបណ្ដាលនៅខេត្តកំពង់ចាម**

- សូមឱ្យមានវគ្គបណ្ដុះបណ្ដាលសុវត្ថិភាពនេះនៅលើកក្រោយៗបន្ថែមទៀត ពិសេសវគ្គស្ដីអំពីសុវត្ថិភាពជនជាតិដើមភាគតិច ពីព្រោះតំបន់ក្រចេះមានខេត្តជាច្រើនដែលមានជនជាតិដើមភាគតិច
- ជាទូទៅចំណេះដឹង និងបទពិសោធន៍នៃផ្នែកសុវត្ថិភាពទាំងបីមានការយល់ដឹងកើនឡើងជាងឆ្នាំកន្លងមក
- សូមឱ្យក្រុមកិច្ចការពារសុវត្ថិភាពចែករំលែកគំរូល្អៗ និង ត្រឹមត្រូវពាក់ព័ន្ធសុវត្ថិភាពទាំងបី ដើម្បីទុកជាគំរូក្នុងការអនុវត្ត
- សូមជួយពង្រឹងសមត្ថភាព និង ចំណេះដឹងបន្ថែមទៀត អំពីការងារសុវត្ថិភាពនេះទៅដល់មន្ត្រីមន្ទីរជំនាញពាក់ព័ន្ធ ។

**វគ្គបណ្ដុះបណ្ដាលនៅខេត្តកំពង់ធំ**

- គួរមានទំនាក់ទំនងល្អជាមួយមន្ទីរជំនាញ ឬអង្គភាពជំនាញផ្សេងទៀត ក្នុងការចុះសិក្សាកិច្ចការពារសុវត្ថិភាពគម្រោង ដើម្បីចៀសវាងនូវបញ្ហាទំនាស់ និងការរាំងស្ទះនានា ។
- សូមឱ្យយកចិត្តទុកដាក់ខ្ពស់លើផលប៉ះពាល់បរិស្ថាន និងសង្គមក្នុងរយៈពេលវែង

- សូមផ្តល់ប្រាក់បេសកកម្មជូនដល់មន្ត្រីជំនាញរបស់មន្ទីរ ឬអង្គភាពពេលចុះជួយគាំទ្រការងារសិក្សាសុវត្ថិភាព
- ពេលបើកវគ្គបណ្តុះបណ្តាលកិច្ចការពារសុវត្ថិភាព គួរលើកបង្ហាញអំពីកំហុសដែលបានកើតឡើងក្នុងការអនុវត្ត មកបង្ហាញឱ្យបានច្បាស់ ហើយយកចំណុចដែលជាកំហុសទាំងអស់នោះមកពិភាក្សា ដើម្បីធ្វើការកែតម្រូវឱ្យបានច្រើន
- សូមឱ្យក្រុមកិច្ចការសុវត្ថិភាពចុះជួយសម្របសម្រួល នែនាំ និងត្រួតពិនិត្យការងារ នៅតាមបណ្តាខេត្តនានាឱ្យបានញឹកញាប់ ដើម្បីជួយពង្រឹងការងារនេះ ជាពិសេសទីប្រឹក្សាប្រចាំតំបន់
- សំណូមពរឱ្យមានបើកវគ្គនេះបន្ថែមទៀតនៅលើកក្រោយ (យ៉ាងតិច១ឆ្នាំម្តង) ហើយវគ្គបណ្តុះបណ្តាលនេះគួរមានរយៈពេលវែងជាងនេះ ហើយគួរតែបើកវគ្គនៅពេលដើមឆ្នាំ (ខែមករា ឬ ខែកុម្ភៈ)
- គួរមានការធ្វើទស្សនៈកិច្ចសិក្សាក្រៅខេត្ត ដើម្បីសិក្សាស្វែងយល់ និងដកបទពិសោធន៍ពីខេត្តផ្សេងៗ (១ឆ្នាំគួរមានទស្សនៈកិច្ចម្តង)
- សំណើរឱ្យរៀបចំមេរៀនអំពីជនជាតិដើមភាគតិច ឱ្យបានលម្អិតជាងនេះបន្តិច ពីព្រោះការងារកិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិច កម្របានជួបប្រទះ និងអនុវត្តជាក់ស្តែងណាស់
- ទីប្រឹក្សាថ្នាក់តំបន់ គួរតែចុះពិនិត្យ និងបញ្ជាក់បច្ចេកទេសការងារសុវត្ថិភាព នៅតាមខេត្តនីមួយៗ ទើបអាចជួយឱ្យដំណើរការគម្រោងបានលឿន និងឆាប់បានដេញថ្លៃទាន់ពេលវេលា
- វិធីសាស្ត្របង្រៀនមានភាពល្អប្រសើរជាងឆ្នាំមុន មានឧទាហរណ៍អំពីការរៀបចំ និងបំពេញទម្រង់នីមួយៗ ដោយបានបង្ហាញយ៉ាងច្បាស់លាស់ និងផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែងរបស់ខេត្តនីមួយៗ។

**សន្និដ្ឋានៈ**

- ជារួមវគ្គបណ្តុះបណ្តាលទាំងបួនវគ្គនេះ សិក្ខាកាមមានការយល់ដឹងច្រើន ដោយសាររាល់បទបង្ហាញទាំងអស់គឺសុទ្ធតែបានផ្សារភ្ជាប់រវាងទ្រឹស្តី ឬគោលការណ៍ណែនាំ ជាមួយនឹងបទពិសោធន៍អនុវត្តជាក់ស្តែងនៅតាមបណ្តាខេត្តនីមួយៗ ។ ជាពិសេសទម្រង់ទាំងឡាយដែលពាក់ព័ន្ធទៅនឹងកិច្ចការពារសុវត្ថិភាពទាំងបី ត្រូវបានបង្ហាញណែនាំ និងពិភាក្សាយ៉ាងលំអិត ។ ទាំងអស់នេះគឺជាវិធីសាស្ត្រដែលញ៉ាំងឱ្យសិក្ខាកាមភាគច្រើនមានការចាប់អារម្មណ៍ ជាមួយសកម្មភាពចូលរួម និង ចែករំលែកបទពិសោធន៍ល្អៗក្នុងវគ្គបណ្តុះបណ្តាលនេះ ។ ការវាយតម្លៃជារួមសិក្ខាកាមមានការយល់ដឹងកាន់តែប្រសើរឡើងជាងបណ្តាឆ្នាំមុនៗ ចំពោះការងារសុវត្ថិភាពទាំងបី ដែលអាចជួយពង្រឹងដល់ការសិក្សា និងរៀបចំគម្រោងនៅតាមបណ្តាមូលដ្ឋាននៃខេត្តនីមួយៗ ។
- ទោះបីជាយ៉ាងណាក៏ដោយ ទាំងមន្ត្រីបង្គោលសុវត្ថិភាពថ្នាក់ខេត្ត មន្ត្រីសម្របសម្រួលខេត្ត/ស្រុក មន្ត្រីគាំទ្របច្ចេកទេស ដែលជាមន្ត្រីចាស់ៗធ្លាប់មានបទពិសោធន៍ច្រើនលើការងារសុវត្ថិភាព មួយចំនួនបានលាឈប់

ហើយត្រូវបានជំនួសដោយមន្ត្រីថ្មីៗ ដែលភាគច្រើននៅមានបទពិសោធន៍តិចតួច ដែលបានចូលរួមក្នុងវគ្គនេះ ។ ដូច្នេះ ដើម្បីពង្រឹងការងារសុវត្ថិភាពទាំងនេះ វគ្គបណ្តុះបណ្តាលប្រភេទនេះនៅតែជាតម្រូវការសំខាន់ សម្រាប់មន្ត្រីពាក់ព័ន្ធនៅថ្នាក់ខេត្ត ដែលថ្នាក់ជាតិត្រូវពិចារណាសម្រាប់បើកវគ្គប្រភេទនេះ នៅពេលក្រោយៗបន្ថែមទៀត ។ ពិសេសការបើកនេះលើកក្រោយ គួរតែអញ្ជើញមន្ត្រីនៃមន្ទីរជំនាញពាក់ព័ន្ធនានា ឱ្យចូលរួមផងដែរ ឧ: មន្ត្រីមន្ទីរបរិស្ថាន មន្ត្រីរដ្ឋបាលជលផល មន្ត្រីរដ្ឋបាលព្រៃឈើ មន្ត្រីមន្ទីររៀបចំដែនដី ជាដើម ។ល។ ការយល់ដឹងរបស់មន្ត្រីជំនាញពាក់ព័ន្ធទាំងនេះ អាចជួយជម្រុញកិច្ចសហការល្អ ជាមួយមន្ត្រីរបស់គ.ប្រ និង ក្រុមប្រឹក្សា ឃុំ សង្កាត់ ចំពោះការងារសិក្សាកិច្ចការពារ សុវត្ថិភាពទាំងបី ឱ្យកាន់តែមានភាពប្រសើរឡើងថែមទៀត ។

- ដើម្បីពង្រឹងកិច្ចការពារសុវត្ថិភាពនេះ ការរៀបចំប្រជុំប្រចាំត្រីមាសស្តីពីការងារសុត្ថិភាពទាំងបី ការរៀបចំទស្សនៈកិច្ចសិក្សាឆ្លងខេត្ត ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្ត និងស្ថាប័នមន្ទីរជំនាញនានា អំពីការងារសុវត្ថិភាព ក៏ជាវិធីសាស្ត្រមួយអាចជួយពង្រឹងកិច្ចការងារសុវត្ថិភាពផងដែរ ។

ភ្នំពេញ ថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ ២០១០

អ្នករៀបចំរបាយការណ៍

**ឃី អាន**